ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

*****************

-----

សំណុំរឿងព្រហ្មទណ្ឌ

លេខៈ ៣៧

ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០០

សាលដីកា

លេខៈ ០២

ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១

## នាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

### បានបើកសវនាការជំនុំជំរះនៅថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១

### ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅៈ

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | ឃឹម | ប៉ុណ្ណ | ប្រធាន |
| ២- | លោក | ឈឹម | ស៊ីផល | ចៅក្រម |
| ៣- | លោក | ប្រាក់ | គីមសាន | ចៅក្រមរបាយការណ៍ |
| ៤- | លោក | វៀល | មួន | ចៅក្រម |
| ៥- | លោក | ជីវ | កេង | ចៅក្រម |
| | លោក | សុខ | ប៊ុនសង | ក្រឡាបញ្ជី |

តំណាងមហាអយ្យការ

| | | | |
|---|---|---|---|
| ឯកឧត្តម | ជួន | ស៊ុនឡេង | អគ្គព្រះរាជអាជ្ញារង |

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ២០ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០( របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ៣៧ ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០០ របស់តុលាការកំពូល ។

ពីបទ : អបោកទ្រព្យសម្បត្តិប្រជាជន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ១៩៩៧ ពាៈ បញ្ញត្តិមាត្រា៤៥ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

-ជនជាប់ចោទ :

១- ឈ្មោះ ផាន់ វ៉ារិន "ម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុសអាយុ ៤៥ឆ្នាំ ជាតិខ្មែរ កើតនៅភូមិលេខ៦ ក្រុងភ្នំពេ( របររកស៊ី លក់ដូរ ទីលំនៅសព្វថ្ងៃផ្ទះលេខ ២៩៤ ផ្លូវម៉ៅសេទុង សង្កាត់ បឹងសាឡាង ខណ្ឌទួលគោក ក្រុងភ្នំពេ( ឪពុកឈ្មោះ ផាន់ បូ (ស្លាប់) ម្តាយឈ្មោះ ទុយ (ស្លាប់) ប្រពន្ធឈ្មោះ សួន គីមហេង មានកូន៥នាក់ ។នៅក្រៅឃុំ

២-ជនជាប់ចោទឈ្មោះ សួន គឹមហេង "ម្ចាស់បណ្តឹងសាទុក្ខ" ភេទស្រី អាយុ ៣៨ ឆ្នាំ ជាតិខ្មែរ កើតនៅ ខេត្ត កំពង់ឆ្នាំង របររកស៊ីលក់ដូរ ទីសំនៅសព្វថ្ងៃ ផ្ទះលេខ២៥៤ ផ្លូវម៉ៅសេទុង សង្កាត់ បឹងសាឡាង ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ឪពុកឈ្មោះ លឹម ឃុន (ស្លាប់) ម្តាយឈ្មោះ លី ម៉ាង (ស្លាប់) ប្តីឈ្មោះ ផាន់ វ៉ារិន មានកូន៥នាក់។ នៅក្រៅឃុំ

- មេធាវីលោក ទូត លុច ការពារអោយជនជាប់ចោទ។

- ដើមបណ្តឹងរដ្ឋប្បវេណី

១- ឈ្មោះ ទេព ល័ក្ខ "ចុងបណ្តឹងសាទុក្ខ" ភេទប្រុសអាយុ ៤៤ ឆ្នាំ ជាតិខ្មែរ របររកស៊ីយោធា ទីលំនៅសព្វថ្ងៃ ភូមិពោងពាយ សង្កាត់ភ្នំពេញថ្មី ខ័ណ្ឌឫស្សីកែវ ក្រុងភ្នំពេញ។

២- ឈ្មោះ សៀក ទៀងហេង "ចុងបណ្តឹងសាទុក្ខ" ភេទប្រុសអាយុ ៣១ ឆ្នាំ ជាតិខ្មែរ របររកស៊ីពាណិជ្ជករ ទីលំនៅ សព្វថ្ងៃ ផ្ទះលេខ ១៧០ដេ ផ្លូវ១៥៥ សង្កាត់ទួលទំពូង១ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ។

-មេធាវីគ្មាន

-លោក សៅ ប៊ុនធុន ជាតំណាងដើមបណ្តឹងរដ្ឋប្បវេណីអោយឈ្មោះ ទេព ល័ក្ខ និង ឈ្មោះ សៀក ទៀងហេង អាយុ ៤៧ឆ្នាំ ជាតិខ្មែរ កើតនៅសង្កាត់ទី ៥ ក្រុងភ្នំពេញ ទីលំនៅសព្វថ្ងៃ ផ្ទះលេខ ១៥៦ អឺមួយផ្លូវម៉ៅសេទុង សង្កាត់ ទឹកល្អក់ ខ័ណ្ឌទួល គោក ក្រុងភ្នំពេញ មុខរបរអ្នកច្បាប់។

- តាមពាក្យបណ្តឹង ចុះថ្ងៃទី ២៣-០៧-៩៧ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ទេព ល័ក្ខ ប្តឹងពីឈ្មោះ ផាន់ វ៉ារិន និង សួន គឹមហេង ពីបទឆបោកម៉ូតូ និង រថយន្ត សរុបទឹកប្រាក់ 32790$ (ដុល្លាអាមេរិក) ។

- តាមកំណត់ហេតុយកចម្លើយ ចុះថ្ងៃទី ០៨-១០-៩៧ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ សៀក ទៀងហេង ឆ្លើយថា ឈ្មោះ ផាន់ វ៉ារិន និង ឈ្មោះ សួន គឹមហេង បានយកម៉ូតូខ្លួនចំនួន២០គ្រឿង និង រថយន្តមួយគ្រឿង ឈ្មោះទាំងនេះមិនទាន់អោយប្រាក់ខ្លួនទេ ខ្លួនសូមប្តឹងទាមទារជំងឺចិត្ត ៨០០០ ដុល្លាអាមេរិក។

- បានឃើញសេចក្តីសន្និដ្ឋាន របស់តំណាងអយ្យការអមតុលាការក្រុងភ្នំពេញ : បានសំរេចចោទប្រកាន់លើ ឈ្មោះ ផាន់ វ៉ារិន និង ឈ្មោះ សួន គឹមហេង ពីបទឆបោកទ្រព្យសម្បត្តិប្រជាជន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ១៩៩៧ តាម បញ្ញត្តិមាត្រា៤៥ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ០១ "ញ" ចុះថ្ងៃទី ០៤-០២-៩៩ របស់តុលាការក្រុងភ្នំពេញដែលបានសំរេច:

១- ផ្តន្ទាទោស ឈ្មោះ ផាន់ វ៉ារិន និង ឈ្មោះ សួន គឹមហេង ដាក់ពន្ធនាគារក្នុងម្នាក់ៗ ២ឆ្នាំ គិតពីថ្ងៃ ចាប់. ឃុំ ពេល សាលក្រមចូលស្ថាពរ។

២- បង្គាប់អោយ ឈ្មោះ ផាន់ វ៉ារិន ,សួន គឹមហេង រួមគ្នាសងប្រាក់ 32790$ (ដុល្លាអាមេរិក) ទៅអោយឈ្មោះ សៀក ទៀងហេង និង ទេព ល័ក្ខ។

ក្នុងករណីទណ្ឌិតមិនព្រមសង ត្រូវដាក់គុកបង្ខំរូបកាយ ដើម្បីទារប្រាក់ធនទណ្ឌ។

៣- បង្គាប់អោយ ឈ្មោះ ផាន់ វ៉ារិន ,សួន គឹមហេង រួមគ្នាសងប្រាក់ជំងឺចិត្ត 5000$ (ដុល្លាអាមេរិក) ទៅអោយឈ្មោះ ទេព ល័ក្ខ និង ឈ្មោះ សៀក ទៀងហេង ។

៤- សាលក្រមនេះជំនុំជំរះ ប្រកាសជាសាធារណៈចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ សំរេចបើកផ្លូវតវ៉ាក្នុងកំណត់ច្បាប់។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ ០៦"ញ ចុះថ្ងៃទី ០៨-០៤-៩៩ របស់ ឈ្មោះ ផាន់ វ៉ារិន ដែលប្តឹងតវ៉ាពីសាលក្រមលេខ ០១ "ញ" ចុះថ្ងៃទី ០៤-០២-៩៩ របស់តុលាការក្រុងភ្នំពេញ លើសេចក្តីសំរេចទាំងមូល។

- បានឃើញសេចក្តីសន្និដ្ឋាន តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ បានសំរេចតម្កល់សាលក្រមលេខ ០១ "ញ" ចុះថ្ងៃទី ០៤-០២-៩៩ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ២០ ចុះថ្ងៃទី ១៩-០១-២០០០ របស់សាលាឧទ្ធរណ៍ដែលបានសំរេច :

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍របស់ ឈ្មោះ ផាន់ វ៉ារិន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់ខុសនឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ០១ "ញ "ចុះថ្ងៃទី ០៤-០២-៩៩របស់តុលាការក្រុងភ្នំពេញ ទុកជាបានការលើកលែងចំណុចទី១ ត្រូវកែប្រែពីទោស២ឆ្នាំ មកព្យួរសាកល្បង ០៥ឆ្នាំវិញ តាមមាត្រា ៧០ ច្បាប់ព្រហ្មទណ្ឌអន្តរកាល។

៣- សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខគូក្តី កំបាំងមុខជនជាប់ចោទ ឈ្មោះ សួន គឹមហេង សំរេចបើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់។

- បានឃើញបណ្តឹងសាទុក្ខលេខ ១៧ ចុះថ្ងៃទី ០៧-០៣-២០០០ របស់ឈ្មោះ ផាន់ វ៉ារិន និង ឈ្មោះ សួន គឹមហេង ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ២០ ចុះថ្ងៃទី ១៩-០១-២០០០ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល។

- បានឃើញសារណាចុះ ថ្ងៃទី ១៦-១០-២០០០ របស់ ឈ្មោះ ផាន់ វ៉ារិន និង ឈ្មោះ សួន គឹមហេង ជាម្ចាស់បណ្តឹងសាទុក្ខធ្វើឡើងក្នុងកំណត់ច្បាប់។

- បានឃើញសារណាតបចុះ ថ្ងៃទី ១៨-១០-២០០០ របស់ ឈ្មោះ ទេព ល័ក្ខ និង ឈ្មោះ សៀក ទៀងហេង ធ្វើឡើងក្នុងកំណត់ច្បាប់។

- បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថា: បើតាមអង្គហេតុ និង ឯកសារឃើញ

ការដែលមានកិច្ចសន្យាគឺជាការប្រើល្បិចកលផ្សេងៗដើម្បីអោយភាគីរងគ្រោះជឿទុកចិត្ត ដោយនៅក្នុងកិច្ចសន្យាសរសេរថា មានប្លង់ផ្ទះបញ្ចាំ តាមការពិតប្លង់ផ្ទះនោះយកទៅដាក់បញ្ចាំនៅធនាគាររួចទៅហើយ នេះជាលក្ខណៈឆបោកពិតប្រាកដ ដូច្នេះឈ្មោះ ផាន់ វ៉ារិន និង នាងសួន គីមហេង ពិតជាមានចេតនាទុច្ចរិតដើម្បីឆបោក លោក សៀក ទ្បេងហេង និង លោក ទេព ល័ក្ខ ពិតប្រាកដមែន។

ហេតុនេះ តំកល់សាលដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល។

- បានស្តាប់ចម្លើយដោះសាររបស់ជនជាប់ចោទ ឈ្មោះ ផាន់ វ៉ារិន នាពេលជំនុំជំរះថា : បានខ្ញុំបាទប្តឹងសាទុក្ខមកតុលាការកំពូលព្រោះ សាលដីកាសាលាឧទ្ធរណ៍សំរេចពុំមានលក្ខណៈត្រឹមត្រូវអោយខ្ញុំបាទទេ ខ្ញុំមិនបានបោកប្រាស់អ្នកណាទេព្រោះរឿងនេះខ្ញុំបានទិញម៉ូតូចំនួន២០គ្រឿងពី ឈ្មោះ សៀក ទ្បេងហេង ក្នុងតម្លៃ 26320$ (ដុល្លាអាមេរិក) ដោយមានវិក័យប័ត្រជាសំគាល់ និង ក្រោយមកខ្ញុំបានទិញឡានមួយគ្រឿងទៀតពីឈ្មោះនេះដោយមានកិច្ចសន្យា លុះក្រោយមកខ្ញុំបានសងទៅ ឈ្មោះ សៀក ទ្បេងហេង ចំនួន5000$(ដុល្លាអាមេរិក)ដោយពុំមានលិខិតស្នាម ព្រោះការរកស៊ីខ្ញុំអាងថាពុំចាំបាច់មានលិខិតស្នាមអ្វីទេគ្រាន់តែហុចទៅហុចមកតែប៉ុណ្ណោះ គឺខ្ញុំបានសងមែន ខ្ញុំគ្មានបំណងបំបាត់ប្រាក់ 5000$ (ដុល្លាអាមេរិក) ទេព្រោះខ្ញុំជំពាក់គេជាង 30000$(ដុល្លាអាមេរិក)ឯណោះ ដូច្នេះក្នុងរឿងនេះខ្ញុំគ្មាន ឆបោកគេទេ ព្រោះការទិញម៉ូតូ និង ឡានពីឈ្មោះ សៀក ទ្បេងហេង ត្រង់ទៅត្រង់មក ហើយនៅមានជំពាក់ប្រាក់ខ្លះនោះ ជារឿង ធម្មតារបស់អ្នករកស៊ីប៉ុណ្ណោះ។

- បានស្តាប់អំណានសារណារបស់ជនជាប់ចោទ ឈ្មោះ សួន គីមហេង ជាម្ចាស់បណ្តឹងសាទុក្ខ នាពេលជំនុំជំរះ។

- បានស្តាប់ចម្លើយអះអាងរបស់ លោក សៅ ប៊ុនធុន តំណាងអោយដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ ទេព ល័ក្ខ និង សៀក ទ្បេងហេង នាពេលជំនុំជំរះថា : មុនដំបូងអ្នកទាំងពីរធ្លាប់រកស៊ីជាមួយគ្នា ខាងជនជាប់ចោទតែងអង្វរអោយធ្វើកិច្ចសន្យាព្រោះខ្លួនពុំទាន់មានលុយ ហើយខ្ញុំជាអ្នកសរសេរកិច្ចសន្យានោះអោយជនជាប់ចោទផ្តាល់ដៃ ដោយក្នុងកិច្ចសន្យានោះមានសរសេរដាក់ប្លង់ផ្ទះ កាលពេលសរសេរកិច្ចសន្យានោះ ភាគីខាងជនជាប់ចោទមិនបាននិយាយថាប្លង់ផ្ទះរបស់ខ្លួនដាក់បញ្ចាំនៅធនាគារទេ ពេលសរសេរមានរដ្ឋអំណាចដឹងឮ ។ រឿងដែលភាគីជនជាប់ចោទថាបានសងមកភាគីខាងខ្ញុំចំនួន 5000$ (ដុល្លាអាមេរិក) នោះគឺគ្មានទេ ព្រោះពួកខ្ញុំមិនបានទទួលសោះឡើយ ហេតុដូច្នេះបានជាពួកខ្ញុំប្តឹងទៅតុលាការក្រុង។

- បានស្តាប់សេចក្តីសន្និដ្ឋាននាពេលសវនាការរបស់ លោក ទូត លុច ជាមេធាវីការពារជនជាប់ចោទ ឈ្មោះ ផាន់ វ៉ារិន និង សួន គីមហេង (ម្ចាស់បណ្តឹងសាទុក្ខ) ថា:

កូនក្តីខ្ញុំបានទិញម៉ូតូចំនួន២០គ្រឿង និង រថយន្តមួយគ្រឿងពី ឈ្មោះ សៀក ទ្បេងហេង មានតម្លៃសរុប 26320$ (ដុល្លាអាមេរិក) តែភាគីខាង សៀក ទ្បេងហេង ចង់បានការប្រាក់ទើបទារពីកូនក្តីរហូតដល់ជាងបីម៉ឺនដុល្លាអាមេរិក។ កាលដែលទិញម៉ូតូ និង រថយន្តគឺមាន វិក័យប័ត្រ និង ធ្វើជាកិច្ចសន្យាជំពាក់យ៉ាងត្រឹមត្រូវរវាងកូនក្តីខ្ញុំ និង ភាគីខាង សៀក ទ្បេងហេង នៅថ្ងៃទី ១២ ខែ មេសា ឆ្នាំ ១៩៩៧។ ក្នុងការធ្វើកិច្ចសន្យានោះភាគីខាង សៀក ទ្បេងហេង សុំអោយកូនក្តីខ្ញុំ

ដាក់បញ្ចាំប្លង់ផ្ទះ តែត្រូវបានកូនក្តីបញ្ជាក់ថាប្លង់ផ្ទះដាក់បញ្ចាំនៅធនាគារហើយ តែ សៀក ទៀងហេង និយាយថាចេះតែដាក់អោយមានសិនទៅ។ ដូច្នេះឃើញថាកូនក្តីខ្ញុំមិនបានបោកប្រាសឬភូតភរកុហកខាង សៀក ទៀងហេងទេ ហេតុនេះទាំងតុលាការក្រុងភ្នំពេញ និង ទាំងសាលាឧទ្ធរណ៍ដែលបានសំរេចចោទកូនក្តីក្នុងរឿងព្រហ្មទណ្ឌពីបទឆបោកនោះពុំត្រឹមត្រូវទេ ព្រោះបើពិនិត្យទៅរឿងនេះជាលក្ខណៈរឿងរដ្ឋប្បវេណីសុទ្ធសាធ ។

- បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែម នាពេលសវនាការ របស់តំណាងមហាអយ្យការ អម តុលាការកំពូលថា:

ទាំងព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ទាំងព្រះរាជអាជ្ញាតុលាការក្រុងភ្នំពេញដែលបានចោទអំពើទាំងនេះជារឿងឆបោកក្នុងរឿងព្រហ្មទណ្ឌគឺជាការត្រឹមត្រូវ ព្រោះការធ្វើកិច្ចសន្យានេះជារូបភាពទុច្ចរិតទៅហើយ ដោយក្នុងកិច្ចសន្យាសរសេរយ៉ាងណាអោយតែភាគីរងគ្រោះសង្ឃឹមនឹងបានលុយមកវិញ។ តាមច្បាប់ភូមិបាលអចលនៈវត្ថុណាបញ្ចាំហើយ យកទៅបញ្ចាំទៀតនោះជារឿងទុច្ចរិតត្រូវតែមានទោស ។ ដូច្នេះអោយតែមានបទល្មើសមិនថាបទល្មើសធ្ងន់ឬបទល្មើលស្រាលនោះទេសុទ្ធតែជាព្រហ្មទណ្ឌទាំងអស់ អញ្ចឹងហើយបានជារឿងនេះនៅសាលាឧទ្ធរណ៍បានសំរេចបន្ថយពីការដាក់គុកមកព្យួរទោសវិញ ។

សូមតម្កល់សាលដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់ជនជាប់ចោទ ឈ្មោះ ផាន់ រ៉ារិន សារណារបស់ជនជាប់ចោទ ឈ្មោះ សួន គឹមហេង , ចម្លើយរបស់តំណាងដើមបណ្តឹងរដ្ឋប្បវេណី និង សេចក្តីសន្និដ្ឋានរបស់មេធាវីជន ជាប់ចោទ ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថាបណ្តឹងសាទុក្ខលេខ១៧ ចុះថ្ងៃទី ០៧ ខែ មិនា ឆ្នាំ ២០០០ របស់ឈ្មោះ ផាន់ រ៉ារិន និង ឈ្មោះ សួន គឹមហេង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថាការលើកឡើងរបស់ឈ្មោះ ផាន់ រ៉ារិន និង ឈ្មោះ សួន គឹមហេង ក្នុងសារណាចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០០ ថាខ្លួនបានទិញម៉ូតូចំនួន២០គ្រឿង និង រថយន្ត០១គ្រឿងពីឈ្មោះ សៀក ទៀងហេង ដោយមានវិក័យប័ត្រ និង កិច្ចសន្យាជំពាក់ជាសំគាល់ ក្រោយមកខ្លួនបានសងចំនួន 5000$ (ប្រាំពាន់ដុល្លាអាមេរិក) ខ្លួនពុំមានចេតនាទុច្ចរិតឡើយ ឯប្រាក់

នៅសល់ខ្លួនសន្យាសងនៅពេលក្រោយ ចំពោះការដែលខ្លួនសរសេរក្នុងកិច្ចសន្យាថាៈបើគ្មានប្រាក់សងខ្លួនសុខចិត្តប្រគល់ផ្ទះលេខ ២៥៤ ផ្លូវម៉ៅសេទុងនោះ ឈ្មោះ សៀក ទៀងហេង បានដឹងរួចមកហើយថាផ្ទះនេះខ្លួនបានយកទៅបញ្ចាំនៅធនាគារតាំងពីឆ្នាំ ១៩៩១ ម្ល៉េះ នោះគឺជាការពុំត្រឹមត្រូវឡើយ ពីព្រោះថាៈ

- តាមកិច្ចសន្យាចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ១៩៩៧ ,ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៩៧ , និង ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ១៩៩៧ ឈ្មោះ ផាន់ វ៉ារិន និង សួន គឹមហេង បានជំពាក់ប្រាក់លោក ទេព ល័ក្ខ និង លោក សៀក ទៀងហេង ក្នុងការទិញម៉ូតូ២០គ្រឿង និង រថយន្តមួយគ្រឿង ចំនួន 26320$ (ដុល្លាអាមេរិក) និង 6470$ (ដុល្លាអាមេរិក) ។ ហើយពុំមានភស្តុតាងណាបញ្ជាក់ថាកិច្ចសន្យានេះធ្វើឡើងដោយមានការបង្ខិតបង្ខំឡើយ ។

- ពុំមានភស្តុតាងណាមួយបញ្ជាក់ថាឈ្មោះ ផាន់ វ៉ារិន និង ឈ្មោះ សួន គឹមហេង បានសងប្រាក់ ចំនួន 5000$ (ប្រាំពាន់ដុល្លាអាមេរិក )អោយលោក ទេព ល័ក្ខ និង លោក សៀក ទៀងហេង ឡើយហើយក៏ពុំមានភស្តុតាងបញ្ជាក់ថា លោក សៀក ទៀងហេង បានដឹងជាមុនថា ផ្ទះលេខ ២៥៤ ត្រូវបានឈ្មោះ ផាន់ វ៉ារិន និង សួន គឹមហេង យកទៅបញ្ចាំនៅធនាគារឡើយ ។

- ដើម្បីអោយ លោក សៀក ទៀងហេង និង លោក ទេព ល័ក្ខ ជឿទុកចិត្ត ឈ្មោះ ផាន់ វ៉ារិន និង ឈ្មោះ សួន គឹមហេង បានប្រើកលល្បិចដោយថា សុខចិត្តប្រគល់ ផ្ទះលេខ ២៥៤ ផ្លូវ ម៉ៅសេទុង លក់ឡាយឡុងសំរាប់ធានាសំណងដែលតាមការពិត ផ្ទះនេះ ត្រូវបានឈ្មោះ ផាន់ វ៉ារិន និង ឈ្មោះ សួន គឹមហេង យកទៅដាក់បញ្ចាំធនាគារកម្ពុជាពាណិជ្ជចំកាត់តាំងពីថ្ងៃ ទី ១២ ខែ តុលា ឆ្នាំ ១៩៩១ម្ល៉េះ ដូច្នេះ ឈ្មោះ ផាន់ វ៉ារិន និង ឈ្មោះ សួន គឹមហេង ពិតជាមានចេតនាទុច្ចរិតក្នុងការឆបោក លោក សៀក ទៀងហេង និង លោក ទេព ល័ក្ខ ប្រាកដមែន។

- យល់ឃើញថាជនជាប់ចោទ ឈ្មោះ សួន គឹមហេង បានធ្វើសារណាការពាររឿងក្ដីរបស់ខ្លួនជូនមកតុលាការរួចហើយ ប៉ុន្តែពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខឈ្មោះនេះ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថាសាលដីកាព្រហ្មទណ្ឌលេខ ២០ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្ដីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ហើយ ។

## ហេតុដូច្នេះ

វិនិច្ឆ័យសេចក្ដីចំពោះមុខ ជនជាប់ចោទ ឈ្មោះ ផាន់ វ៉ារិន និង តំណាងដើមបណ្ដឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ ឈ្មោះ សួន គឹមហេង ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

១- ទទួលបណ្ដឹងសាទុក្ខលេខ១៧ ចុះថ្ងៃទី ០៧ ខែ មិនា ឆ្នាំ ២០០០ របស់ឈ្មោះ ផាន់ វ៉ារិន និង ឈ្មោះ សួន គឹមហេង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ២០ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣- សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ។